ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៤៦/២០-សណ្ឋាគារ ឡឺម៉េរីឌានអង្គរ

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង វួចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ស៊ីន គីមស៊ាន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ឌិ អ៊ឹមភៀរៀល អង្គរ តែលេស ហូថេល (សណ្ឋាគារ ឡឺម៉េរីឌានអង្គរ)**

អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ ៖ ០១២ ៧៧៧ ៣៨០ / ០១១ ៨៤៤ ១៨៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

| | |
|---|---|
| ១- លោក កុំ ប៊ុនផាន់ | មេធាវី |
| ២- លោក អ៊ុក គឹមឡេង | មេធាវី |
| ៣- លោក លី ប៊ុនហួរ | នាយកធនធានមនុស្ស |
| ៤- លោកស្រី ទូច អង្គឧសភា | នាយកផ្នែកលក់ និងទីផ្សារ |
| ៥- លោក ប៊ុន ផាន់ថង | ជំនួយការមេធាវី |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃ ឌិ អ៊ឹមភៀរៀល អង្គរ តែលេស ហូថេល (សណ្ឋាគារ ឡឺម៉េរីឌានអង្គរ)**

អាសយដ្ឋាន ៖ ភូមិថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប

ទូរស័ព្ទ ៖ ០៨៦ ៧៥ ៦៦ ៤២ / ០៩៥ ៨១ ៥៥ ៨៩ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- (ចំណុចទី២) ភាគីកម្មករនិយោជិតស្នើសុំឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលសម្រាប់បុគ្គលិកធម្មតា កម្រិត ១ កម្រិត២ និងកម្រិត៣ ពី ៦៥% មក ៨០% នៃប្រាក់ឈ្នួលគោល ដោយមូលហេតុបុគ្គលិកមិនអាចយកប្រាក់ខែនេះ ទៅផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃឡើយ។

២- (ចំណុចទី៣) ភាគីកម្មករនិយោជិតទាមទារឱ្យចាត់វិធានការតាមផ្លូវច្បាប់ ទៅលើអ្នកគ្រប់គ្រងសណ្ឋាគារ ឡឺម៉េរីឌានអង្គរ ដែលបានប្រើកាយវិការ ពាក្យសម្តីគំរាមកំហែង រុកគួន បៀតបៀន រើសអើង និងដាក់សម្ពាធមកលើបុគ្គលិកជាច្រើនដង ដើម្បីឱ្យបុគ្គលិកលាឈប់ពីការងារ មានឈ្មោះដូចខាងក្រោម ៖

- លោកស្រី សាប្រីណា ចាកុប តួនាទី General Manager
- លោក លី ប៊ុនហួរ តួនាទី Director of Human Resource
- លោក ហ៊ោង សុជា តួនាទី Director of QA in Charge L&D
- លោកស្រី ចិន ផល្លា តួនាទី Assistant Director of Sale
- លោកស្រី ជុំ បញ្ញារ័ត្ន តួនាទី Finance Manager

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួម នៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ លេខ ០៥៦ ម.ក.ប ចុះថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ ស្នើសុំឱ្យជួយដោះស្រាយវិវាទការងារចំនួន ៣ ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប បានអញ្ជើញ

THE ARBITRATION COUNCIL

ភាគីទាំងពីរមកចូលរួមដោះស្រាយវិវាទការងាររួម នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមរវាងសណ្ឋាគារ ឡឺម៉េរីឌានអង្គរ និងកម្មករនិយោជិតនៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ លេខ ០៥៦ ម.ក.ប ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ បានបញ្ជាក់ថា ចំណុចវិវាទទី១ ពាក់ព័ន្ធទៅនឹងការទាមទារឱ្យទទួលយកសកម្មជនសហជីពចំនួន ៣រូប ចូលធ្វើការវិញ និងបើកប្រាក់រំលឹក ចាប់ពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ អ្នកផ្សះផ្សានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវដោះស្រាយជាលក្ខណៈវិវាទបុគ្គល ដោយសម្រេចមិនបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះស្រាយលើចំណុចនេះទេ។ ហេតុនេះ ចំណុចវិវាទមិនសះជាដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវិវាទចំនួន ២ចំណុច ដូចមាននៅក្នុងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមតែប៉ុណ្ណោះ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជកមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ២ចំណុច នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ នៅវេលាម៉ោង ១៤ និង ០០ នាទី រសៀល តាមរយៈលិខិតអញ្ជើញលេខ ៣០១ កប/អក/វក/លកអ. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ទៅភាគីនិយោជក និងលិខិតអញ្ជើញលេខ ៣០២ កប/អក/វក/លកអ. ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ទៅភាគីកម្មករនិយោជិត។ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ១៤ និង ១០ នាទី រសៀល ភាគីកម្មករនិយោជិតបានដាក់លិខិតជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្នើសុំពន្យារពេលសវនាការ ដោយរង់ចាំការប្រជុំរកដំណោះស្រាយនៅរដ្ឋបាលខេត្តសៀមរាប។ ក្រោយពីទទួលបានលិខិតស្នើសុំពន្យារពេលសវនាការពីភាគីកម្មករនិយោជិត នៅថ្ងៃដដែលនេះ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការទំនាក់ទំនងទៅភាគីនិយោជក ដើម្បីជម្រាបជូនអំពីការស្នើសុំពន្យារពេលសវនាការនេះ។ ដោយឡែក ភាគីនិយោជកមិនយល់ព្រមលើកពេលសវនាការនេះទេ។ ដោយមិនមានការឯកភាពរវាងភាគីទាំងពីរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចដំណើរការសវនាការ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀលដដែល។ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ៨ និង ០០ នាទី ព្រឹក ភាគីកម្មករនិយោជិតបានដាក់លិខិតជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីជូនដំណឹងស្តីពីការមិនចូលរួមនីតិវិធីសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយសារមិនឯកភាពតាមការសម្រេចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ដែលបានសម្រេចបំបែកសំណុំរឿងនេះជាពីរ ដោយចាត់ទុកចំណុចវិវាទទី១ ជាចំណុចវិវាទបុគ្គលផ្ទុយនិងខ្លឹមសារមាត្រា ៣០២ នៃច្បាប់ស្តីពីការងារ។

នៅថ្ងៃសវនាការ ភាគីនិយោជកមានវត្តមានតាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញា-កណ្តាល។ ដោយឡែក ភាគីកម្មករនិយោជិតមិនមានវត្តមាននៅថ្ងៃសវនាការ តាមការអញ្ជើញរបស់លេខា-ធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ របស់លោកស្រី សាប្រីណា ដេកុប ជានាយកសណ្ឋាគារ ឡឺម៉េរីឌានអង្គរ ផ្ទេរសិទ្ធិជូនលោក កុំ ប៊ុនផាន់ ជាមេធាវីតំណាងដោយអាណត្តិ។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម សណ្ឋាគារ ឌិ អ៊ីមភៀរៀល អង្គរ តៃលេស ហូថេល លេខ MOC-២១៨៧៥៥៤៥ ពណ.ចបព ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០០។

៣- លក្ខន្តិកៈសណ្ឋាគារ ឌិ អ៊ីមភៀរៀល អង្គរ តៃលេស ហូថេល បានតម្កល់ទុកលេខ ០០០១៨៧៥៧ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៩ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៤- បទបញ្ជាផ្ទៃក្នុងសណ្ឋាគារ ឌិ អ៊ីមភៀរៀល អង្គរ តៃលេស ហូថេល ចុះទិដ្ឋាការ លេខ ៣១ ក.ប.វ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។

៥- លិខិតចុះថ្ងៃចន្ទ ៦កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ របស់ការិយាល័យមេធាវីអន្តរជាតិ ប៊ុនផាន់ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាសង្ខេបនៅក្នុងសំណុំរឿងលេខ ០៤៦/២០ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

៦- កិច្ចព្រមព្រៀងអនុសញ្ញារួម រវាងសហជីពនិយោជិតនៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ និងសណ្ឋាគារ ឡឺម៉េរីឌានអង្គរ នៃក្រុមហ៊ុន ម៉ារីយ៉ត មានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

៧- លិខិតព្រមានលេខ ០០១ ម.ក.ប ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប ជម្រាបមកលោក លី លីនដា ប្រធានសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ នៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ ស្តីពីការព្រមានចំពោះសកម្មភាពរបស់លោកដែលបានប្រព្រឹត្តល្មើសនិងនិតិវិធីច្បាប់។

៨- លិខិតព្រមានលេខ ០០២ ម.ក.ប ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមកលោក ទូច កុសល ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ ស្តីពីការព្រមានចំពោះសកម្មភាពរបស់លោកដែលបានប្រព្រឹត្តល្មើស និងនិតិវិធីច្បាប់។

៩- លិខិតលេខ ១១៦១/២០ សជណ ចុះថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តសៀមរាប ជម្រាបមកលោក ទូច កុសល ប្រធានសហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ លោក លី លីនដា ប្រធានសហជីពកម្មករនិយោជិតវិស័យទេសចរណ៍ នៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ លោកប្រធានសហជីពកម្មករនិយោជិតនៃក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា និងលោក ម៉េត រាត ប្រធានសហជីពកម្មករនិយោជិតនៃរោងចក្រ ផេក ជីក ស្តីពីផ្អាកការធ្វើកូដកម្មដោយសន្តិវិធីនៅមុខសណ្ឋាគារ ឡឺម៉េរីឌានអង្គរ ក្រុមហ៊ុន ភូមិវប្បធម៌កម្ពុជា និងរោងចក្រ ផេកជីក។

១០- ឯកសារបង្ហោះសារនៅលើទំព័រ Facebook Page របស់រដ្ឋបាលខេត្តសៀមរាប។

១១- លិខិតលេខ ០១៧ ម.ក.ប ចុះថ្ងៃសុក្រ ១២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ជម្រាបមកលោក លី លីនដា ប្រធានសហជីពកម្មករនិយោជិតវិស័យទេសចរណ៍នៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ ស្តីពីករណីជួបជុំគ្នា របស់លោក និងសមាជិកសហជីពរបស់លោក នៃសណ្ឋាគារ ឡឺម៉េរីឌាន អង្គរ។

១២- កម្រងឯកសាររូបភាព។

១៣- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- ពាក្យសុំពន្យាពេល ចុះថ្ងៃអង្គារ ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ របស់តំណាងភាគីកម្មករនិយោជិតនៃសណ្ឋាគារ ឡឺម៉េរីឌាន អង្គរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការសុំពន្យាពេលសវនាការ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ ក្នុងសំណុំរឿងលេខ ០៤៦/២០ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- លិខិតជូនដំណឹង ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ របស់តំណាងភាគីកម្មករនិយោជិត នៃសណ្ឋាគារ ឡឺម៉េរីឌាន អង្គរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនដំណឹងពីការមិនចូលរួមសវនាការ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៤៦/២០ ករណីសណ្ឋាគារ ឡឺម៉េ រីឌានអង្គរ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅសណ្ឋាគារ ឡឺម៉េរីឌានអង្គរ លេខ ០៥៦ ម.ក.ប ចុះថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅសណ្ឋាគារ ឡឺម៉េរីឌានអង្គរ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃសណ្ឋាគារ ឡឺម៉េរីឌានអង្គរ លេខ ០០០៦/០៨/២០ ម.ក.ប ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តសៀមរាប។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣០១ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣០២ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០។

THE ARBITRATION COUNCIL

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញា-កណ្តាលទេ ដោយសារភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងមិនបានចូលរួមសវនាការ តាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងត្រូវបន្តនីតិវិធីអាជ្ញា-កណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹង ?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្រុមអាជ្ញា-កណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត"*។

ប្រការ ២០ នៃប្រកាសដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

ប្រការ ២១ នៃប្រកាសដដែលនេះ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល" នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ដែលបានលើកឡើងខាងលើនេះមានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួន និងមិនចូលរួមសវនាការ។ *(សូមមើលបន្ថែមសំណុំរឿងលេខ ១៦/០៧-ឡូទូសត៏, លេខ ២៧/០៧-អ៊ីម និង រ៉េ៣,*

*លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជួន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ហ្វ្រែង, លេខ ១០៨/១៣-អាត់តូ និងលេខ ៣៣២/ ១៤-ធី & ខេ ហ្វារមេន)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្ដាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតមិនមានវត្តមាននៅក្នុងសវនាការអាជ្ញាកណ្ដាល នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សា-អាជ្ញាកណ្ដានោះទេ ដោយនៅព្រឹកថ្ងៃសវនាការដដែលនោះ ភាគីកម្មករនិយោជិតក៏បានដាក់លិខិតជូនក្រុម-ប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីជូនដំណឹងស្ដីពីការមិនចូលរួមនីតិវិធីសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដោយសារមិនឯកភាពតាមការសម្រេចរបស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តសៀមរាប ដែលបានសម្រេចបំបែកសំណុំរឿងនេះជាពីរ ដោយចាត់ទុកចំណុចវិវាទទី១ ជាចំណុចវិវាទបុគ្គល ផ្ទុយនិងខ្លឹមសារមាត្រា ៣០២ នៃច្បាប់ស្ដីពីការងារ។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការជំទាស់នឹងការសម្រេចរបស់មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តសៀមរាប គឺមិនអាចយកមកធ្វើជាមូលដ្ឋានក្នុងការមិនចូលរួមសវនាការអាជ្ញាកណ្ដាលបានទេ ដោយហេតុថា ភាគីវិវាទត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សា-អាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម ផ្អែកតាប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្ដីពីក្រុមប្រឹក្សាអាជ្ញា-កណ្ដាល។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលចាត់ទុកថា ការមិនបង្ហាញខ្លួនរបស់កម្មករនិយោជិតដែលជាដើមបណ្ដឹង នៅថ្ងៃសវនាការនេះ គឺជាការបោះបង់ចោលពាក្យបណ្ដឹងរបស់ខ្លួន ដោយហេតុថា ភាគីដើមបណ្ដឹងមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីបំពេញនូវកាតព្វកិច្ចផ្ដល់អំណះអំណាង ហេតុផល និងភស្តុតាង ដើម្បីការពារបណ្ដឹងរបស់ខ្លួន។

សរុបសេចក្ដីមក យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល សម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលសំណុំរឿងលេខ ០៤៦/២០-សណ្ឋាគារ ឡឺម៉េរីឌាន អង្គរ ដោយចេញសេចក្ដីបង្គាប់។

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលនៃសំណុំរឿងលេខ ០៤៦/២០-សណ្ឋាគារ ឡឺម៉េរីឌាន អង្គរ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **សេខ ឡូចហ៊ុន**

ហត្ថលេខា ៖ ----------------------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ស៊ីន គីមស៊ាន**

ហត្ថលេខា ៖----------------------------------------------

**ប្រធានក្រុមអាជ្ញាកណ្ដាល ៖**

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា ៖ ----------------------------------------------